## I. ផ្សព្វផ្សាយនយោបាយ (Advertising of political)

ជាការពិតណាស់ ការផ្សព្វផ្សាយនយោបាយមិនមែនទើបតែមាននោះទេនៅក្នុងសង្គមកម្ពុជា ក៏ដូចជាប្រទេសកម្ពុជា គឺវាមានតាំងតែពីមានការបង្កើតគណបក្សនយោបាយមកម្ល៉េះ ដូចដែលបានសឲ្យឃើញនៅសម័យនៃការបង្កើតគណបក្សប្រជាជនបដិវត្តន៏កម្ពុជា ជាដើម ។ ប៉ុន្តែកម្រិតនៃការផ្សព្វផ្សាយវាត្រូវបានកំណត់ទៅតាមនិន្នាការនៃសង្គមជាក់ស្តែងផងដែរ ដែលមានន័យថាការផ្សព្វផ្សាយ ឬការដែលគេហៅម៉្យាងទៀតថា ការឃោសនានោះពីមុនមកមានត្រឹមតែការបង្ហាញនៅតាមតំបន់នីមួយៗ ឬក៏ជាការឃោសនាដោយផ្ទាល់ ដែលមានលលក្ខណះបុរាណប៉ុណ្ណោះ ។

បច្ចុប្បន្នដោយប្រទេសកម្ពុជា ជាប្រទេសមួយដែលកំពុងមានការអភិវឌ្ឍន៏ និងកំពុងទទួលបាននូវបច្ចេកវិទ្យាទំនើបៗផងនោះ ប្រទេសកម្ពុជា ក៏ដូចជាបក្សនយោបាយនៅប្រទេសកម្ពុជាបានផ្លាស់ប្តូរនិងបន្ថែមនូវរបៀបរបបនៃការផ្សព្វផ្សាយ ឬការឃោសនានយោបាយរបស់ខ្លួនជាបន្តបន្ទាប់ដែលនាំឲ្យគណះបក្សរបស់ពួកគេមានភាពលេចធ្លោ និងមានប្រជាជនស្គាល់កាន់តែច្រើនថែមទៀត។

មិនចំពោះតែនៅកម្ពុជានោះទេ ប្រទេសមួយចំនួនទៀតនៅលើសកលលោកដែលមិនប្រកាន់យកនូវរបបកុម្មុយនីស្ត(ផ្តាច់ការ) នូវរាល់គណបក្សទាំងឡាយដែលឈរឈ្មោះដើម្បីទទួលបានការគាំទ្រពីប្រជាជន ពួកគេបានខិតខំរិះរកនូវរាល់មធ្យោបាយជាច្រើនដើម្បីផ្តល់ទំនុកចិត្តទៅដល់ប្រជាជននៅក្នុងប្រទេសរបស់ពួកគេ ដោយមានការបង្កើតបណ្តាញសង្គមនៃបក្សនយោបាយរបស់ពួកគេដូចជា ៖ **ការបង្កើតឲ្យមានសកម្មជននៅតាមខេត្តក្រុង ការបង្កើតបណ្តាញសង្គមហ្វេសបុក ការបង្កើតគេហទំព័រ ឬប្លុកដែលមានបង្ហោះអំពីរបបនៃនយោបាយរបស់ប្រធានបក្ស ការបង្ហាញតាមរយះការសែត ទូរទស្សន៏ និងវិទ្យុ** ។ល។ ហើយគេក៏មិនបានបោះបង់ផងដែរនូវរបៀបនៃការផ្សព្វផ្សាយដែលមានតាំងពីយូរនោះមក គឺការ

ផ្សព្វផ្សាយដោយផ្ទាល់ ដែលមានន័យថាវាគឺការបង្កើតឲ្យមានសកម្មជននៅតាមបណ្ដាភូមិ ស្រុក ខេត្តនិងក្រុងនោះឯង ។ ជាក់ស្ដែងនៅក្នុងរបបសង្គមរាស្ត្រនិយម សម្ដេចព្រះនរោត្តម សីហនុ ទ្រង់បានតែងតាំងមេឃុំជាប្រធានសាខាបក្សតែម្ដង។ ដែលវានាំឲ្យមានភាពងាយស្រួលក្នុងការផ្ដល់ពត៍មានផ្សេងៗដល់ប្រជាជន និងជាភាពងាយស្រួលក្នុងការផ្ដល់នូវជំនឿទុកចិត្តដល់ប្រជាជនផងដែរ ។

- **បណ្ដាញសង្គមហ្វេសបុក**

  បច្ចុប្បន្នយើងឃើញហើយថាយុវជនក៏ដូចជាមនុស្សមួយភាគធំនៅលើសកលលោកបាននឹងកំពុងមានទំនោរទៅលើបណ្ដាញហ្វេសបុកជាខ្លាំង មិនថាប្រុស ស្រី ចាស់ ឬក្មេងនោះទេ។ ខ្ញុំសូមលើកយកអំពីបណ្ដាញហ្វេសបុកនៅ
  កម្ពុជាមកនិយាយតែម្ដង គឺមួយភាគធំនៅកម្ពុជាបណ្ដាញហ្វេសបុកមានទំនោរខ្លាំងទៅរកយុវជន ក្មេងៗ និងអ្នកនយោបាយជាខ្លាំង ។ អ្នកនយោបាយនៅកម្ពុជា ក៏ដូចជា
  សកម្មជននៃគណៈបក្សនីមួយៗបានប្រើប្រាស់បណ្ដាញ
  ហ្វេសបុកជាផ្នែកមួយដែលមានសារៈសំខាន់ផងដែរ សម្រាប់ការបង្ហោះផ្សព្វផ្សាយអំពីរបបនយោបាយថ្មីៗ នយោបាយឈ្នះៗរបស់ខ្លួននៅក្នុងហ្វេសបុក ដើម្បីឲ្យយុវ
  វ័យឬអ្នកលេងបានយល់ដឹងនិងបានឃើញនូវរបបនយោបាយ
  របស់ខ្លួន ដែលជាកត្តាមួយនៃការផ្ដល់នូវទំនុកចិត្តដល់ពួកគេក្នុងការបោះឆ្នោតផងដែរ ។

- **ការបង្កើតគេហទំព័រ ឬប្លុក**

  ចំពោះការធ្វើនយោបាយគឺមិនមែនតែការផ្ដល់ជាពត៍មានដល់ប្រជាជនខ្លួនឯងឲ្យបានដឹងវារួចស្រេចនោះទេ ព្រោះថាការធ្វើនយោបាយប្រជាធិបតេយ្យនេះមានប្រទេសជាច្រើនដែលបាន

អនុវត្តន៍ផងដែរ ដូចនេះអ្នកនយោបាយគឺចាំបាច់ត្រូវបង្កើតឲ្យមាននូវគេហទំព័រផ្ទាល់ខ្លួនរបស់ពួកគេដើម្បីបង្ហោះចូលនូវរបបនយោបាយរបស់ពួកគេ និងកិច្ចការថ្មីៗ ក៏ដូចជាបញ្ហាជាច្រើនដែលពាក់ពន្ធ័និងនយោបាយរបស់ពួកគេដើម្បីផ្តល់ឲ្យមនុស្សនៅលើសកលលោកបានយល់ដឹង ដោយមិនគិតពីជាតិសាសន៍នោះទេ ។ វាក៏ចាំបាច់ផងដែរ ព្រោះថាការបានការគាំទ្រពីសំណាក់អ្នកនយោបាយបរទេស ឬការពេញចិត្តពីបរទេសអាចជួយដល់ប្រទេសមួយចំនួន នោះគឺការបង្កើតបាននូវការទំនាក់ទំនងជាអន្តរជាតិ ការប្រមូលនូវហិរញ្ញវត្ថុបានពីការទទួលភ្ញៀវទេសចរណ៍(ផលប្រយោជន៍ពីការធ្វើនយោបាយដែលមានសន្តិភាព)។

- **ការបង្ហាញតាមការសែត**

ការសែតគឺបានដើរតួយ៉ាងសំខាន់មួយផងដែរសម្រាប់ការផ្សព្វផ្សាយនយោបាយ ព្រោះថាមនុស្សវ័យចំណាស់មួយចំនួនមានទំនោរខ្លាំងទៅរកការអាន មើល និងតាមដានការសែតដែលបានចេញផ្សាយជារៀងរាល់ថ្ងៃពិសេសគឺបញ្ហាការធ្វើនយោបាយរបស់រាជរដ្ឋាភិបាល។ ចំពោះកម្ពុជាក្រុមហ៊ុនការសែតដែលមានភាពលេចធ្លោរជាងគេនោះមានដូចជាៈ ការសែតកោះសន្តិភាព ការសែតដើមអំពិល...ជាដើម។ ពួកគេបានចុះផ្សាយអំពីបញ្ហានយោបាយ និងព្រឹត្តិការណ៍ថ្មីៗជារៀងរាល់ថ្ងៃ និងជាច្រើនផងដែរហើយមានភាពឆាប់រហ័សទៀតផង ។ ការសែតគឺមានភាពងាយស្រួលដល់មនុស្សជាច្រើនដែលចង់ដឹងអំពីបញ្ហានយោបាយថ្មីៗ ជាពិសេសបើតាមការកត់សម្គាល់របស់ខ្ញុំគឺប្រជាពលរដ្ឋដែលប្រកបមុខរបររត់ម៉ូតូឌុប ពួកគាត់តែងតែទិញការសែតដើម្បីបានដឹងនូវព្រឹត្តិការណ៍ថ្មីៗជាច្រើន ហើយមិនតែប៉ុណ្ណោះពួកគាត់បាន

បន្តផ្សព្វផ្សាយបញ្ហាទាំងនោះទៅដល់មនុស្សជាច្រើនទៀតជាបន្តបន្ទាប់ ។

**សរុបមក**ការធ្វើនយោបាយតាមបច្ចេកវិទ្យាទំនើបខាងលើបានជួយដល់គណៈបក្សនយោបាយបានយ៉ាងច្រើនដើម្បីទាញយកទំនុកចិត្តពីប្រជាពលរដ្ឋក្នុងកំឡុងពេលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ របស់រាជរដ្ឋាភិបាលជាប្រាកដ ។